RHODE ISLAND DEPARTMENT OF HEALTH

# អ្វីដែលត្រូវដឹងអំពីវ៉ាក់សាំង

**វ៉ាក់សាំងជួយសង្គ្រោះជីវិត និងការពារយើង មនុស្សជាទីស្រលាញ់របស់យើង និងសហគមន៍របស់យើងមិនឱ្យកើតមានជំងឺធ្ងន់ធ្ងរដូចជា កញ្ជ្រឹល គ្រុនផ្តាសាយ ជំងឺអុតស្វាយ ក្អកមាន់ និងជំងឺជាច្រើនទៀត។**

## ហេតុអ្វីត្រូវចាក់វ៉ាក់សាំង?

- វ៉ាក់សាំងជួយប្រព័ន្ធការពារពីកំណើតរបស់រាងកាយអ្នកប្រឆាំងនឹងជំងឺផ្សេងៗ។ នៅពេលអ្នកបានចាក់វ៉ាក់សាំង ប្រព័ន្ធភាពស៊ាំរាងកាយរបស់អ្នកនឹងរៀនស្គាល់ និងប្រយុទ្ធប្រឆាំងនឹងមេរោគនោះ ហើយវាការពារអ្នកមិនឱ្យឆ្លងមេរោគនៅពេលអនាគត។
- វ៉ាក់សាំងជួយការពារកុំឱ្យកើតជំងឺធ្ងន់ធ្ងរ។ វ៉ាក់សាំងខ្លះក៏អាចការពារជំងឺមហារីកមួយចំនួនផងដែរ។
- ការចាក់វ៉ាក់សាំងអាចជួយការពារអ្នកដែលមិនអាចទទួលបានវ៉ាក់សាំងជាក់លាក់ណាមួយ ដូចជាទារក មនុស្សចាស់ និងមនុស្សដែលមានប្រព័ន្ធភាពស៊ាំរាងកាយចុះខ្សោយ។
- វ៉ាក់សាំងមានសុវត្ថិភាព និងត្រូវបានអនុម័តដោយអ្នកជំនាញវេជ្ជសាស្ត្រ។
- **វ៉ាក់សាំងជាច្រើនគឺមិនគិតថ្លៃ ឬមានតម្លៃទាប។**

## តើអ្នកណាត្រូវចាក់វ៉ាក់សាំង?

វ៉ាក់សាំងមិនមែនសម្រាប់តែទារកទេ! វ៉ាក់សាំងមានសារៈសំខាន់សម្រាប់មនុស្សគ្រប់វ័យ - រាប់ចាប់ពីកុមារ និងក្មេងជំទង់ដល់មនុស្សធំ និងមនុស្សចាស់។

## ពេលណាត្រូវចាក់វ៉ាក់សាំង

ពិភាក្សាជាមួយវេជ្ជបណ្ឌិតអំពីវ៉ាក់សាំងដែលអ្នក និងគ្រួសាររបស់អ្នកត្រូវការ។ ដើម្បីស្វែងយល់បន្ថែមអំពីវ៉ាក់សាំងដែលត្រូវបានណែនាំតាមកម្រិតអាយុ និងតាមដំណាក់កាលផ្សេងៗគ្នា សូមចូលទៅកាន់ health.ri.gov/vaccines.

## កន្លែងដែលត្រូវទទួលបានការចាក់វ៉ាក់សាំង

អ្នកអាចស្វែងរកគ្លីនិក និងកម្មវិធីវ៉ាក់សាំងក្នុងស្រុកនៅកន្លែងទាំងនេះ៖

- Asthenis Public Health Hub (401-473-3958): ផ្តល់វ៉ាក់សាំងជាច្រើនសម្រាប់៖
  - កុមារដែលគ្មានគម្រោងធានារ៉ាប់រងសុខភាព ឬគ្រូពេទ្យប្រចាំ។
  - មនុស្សពេញវ័យដោយគ្មានគម្រោងធានារ៉ាប់រងសុខភាព។
  - មនុស្សពេញវ័យដែលមានគម្រោងធានារ៉ាប់រងសុខភាព ដែលមិនអាចបង់ថ្លៃទាំងអស់ ឬថ្លៃខ្លះសម្រាប់វ៉ាក់សាំង។
- ចាក់វ៉ាក់សាំងមុនពេលអ្នកបញ្ចប់ការសិក្សា (Vaccinate Before You Graduate)៖ កម្មវិធីដើម្បីជួយសិស្សថ្នាក់អនុវិទ្យាល័យ និងវិទ្យាល័យ បន្តទទួលបានការចាក់វ៉ាក់សាំងរបស់ពួកគេ។ ទូរសព្ទទៅខ្សែព័ត៌មានសុខភាពតាមលេខ 401-222-5960 / RI Relay 711 ដើម្បីស្វែងយល់បន្ថែម។

## ព័ត៌មានសម្រាប់អ្នកដំណើរ

ពេលធ្វើដំណើរទៅក្រៅប្រទេស អ្នកអាចប្រឈមនឹងជំងឺផ្សេងៗ។ វាមានសារៈសំខាន់ខ្លាំងណាស់ដែលអ្នក និងសមាជិកគ្រួសាររបស់អ្នកបានចាក់វ៉ាក់សាំងដែលបានធ្វើបច្ចុប្បន្នភាពចុងក្រោយបង្អស់ មុនពេលអ្នកធ្វើដំណើរ។ ការចាក់វ៉ាក់សាំងមួយចំនួនគឺត្រូវបានតម្រូវឱ្យចាក់ ឬណែនាំឱ្យចាក់ មុនពេលធ្វើដំណើរទៅក្រៅប្រទេស។ វ៉ាក់សាំងខ្លះត្រូវការច្រើនជាងមួយដូសដើម្បីការពារបានពេញលេញ។ ចាប់ផ្តើមរៀបចំផែនការសម្រាប់វ៉ាក់សាំងធ្វើដំណើរ ពីបួនទៅប្រាំមួយសប្តាហ៍មុនពេលអ្នកធ្វើដំណើរ។

សម្រាប់ជំនួយក្នុងការស្វែងរកគ្លីនិកវ៉ាក់សាំងសម្រាប់អ្នកធ្វើដំណើរ សូមចូលទៅកាន់ health.ri.gov/immunization/information/travelers ឬ ទូរសព្ទទៅលេខ 401-222-5960 / RI Relay 711។

# វ៉ាក់សាំង៖ ទទួលបានការពិត

វាមានសារៈសំខាន់ណាស់ក្នុងការយល់ដឹងពីការពិតអំពីវ៉ាក់សាំង ដើម្បីធ្វើការសម្រេចចិត្តនៅពេលទទួលបានព័ត៌មានគ្រប់ជ្រុងជ្រោយអំពីសុខភាពរបស់អ្នក និងសុខភាពគ្រួសាររបស់អ្នក។

☒ **ជំនឿខុស៖** មនុស្សគួរតែចាក់វ៉ាក់សាំង ដោយសារតែវាត្រូវបានតម្រូវឱ្យចាក់។

☑ **ការពិត៖** ខណៈពេលដែលការតម្រូវឱ្យចាក់វ៉ាក់សាំងគឺត្រូវបានលើកទឹកចិត្តឱ្យធ្វើ ដើម្បីជាការបង្ការបែបទូលំទូលាយ ប៉ុន្តែហេតុផលដ៏ល្អបំផុតនោះគឺ ការចាក់វ៉ាក់សាំងដើម្បីការពារសុខភាពរបស់អ្នក និងសុខភាពរបស់មនុស្សជុំវិញខ្លួនអ្នក។

☒ **ជំនឿខុស៖** ខ្ញុំអាចចាក់វ៉ាក់សាំងបានតែនៅការិយាល័យវេជ្ជបណ្ឌិតរបស់ខ្ញុំប៉ុណ្ណោះ។

☑ **ការពិត៖** អ្នកក៏អាចទទួលបានវ៉ាក់សាំងនៅឱសថស្ថានគ្លីនិកវ៉ាក់សាំង សាលារៀន និងកន្លែងធ្វើការផងដែរ។

☒ **ជំនឿខុស៖** វ៉ាក់សាំងអាចមានសារធាតុគ្រោះថ្នាក់ជាច្រើន។

☑ **ការពិត៖** វ៉ាក់សាំងមានសុវត្ថិភាព ដោយមានធាតុផ្សំដែលត្រូវបានធ្វើតេស្តយ៉ាងប្រុងប្រយ័ត្ន ដើម្បីសុវត្ថិភាព។ វ៉ាក់សាំងមានធាតុផ្សំក្នុងកម្រិតដូសដែលទាបជាងកម្រិតដូសដែលយើងអាចនឹងប៉ះពាល់ដោយធម្មជាតិនៅក្នុងបរិស្ថានរបស់យើងទៅទៀត។

☒ **ជំនឿខុស៖** វ៉ាក់សាំងអាចផ្លាស់ប្តូរ DNA របស់ខ្ញុំ។

☑ **ការពិត៖** វ៉ាក់សាំងមិនផ្លាស់ប្តូរ ឬធ្វើអន្តរកម្មជាមួយ DNA របស់អ្នកទេ។

☒ **ជំនឿខុស៖** វ៉ាក់សាំង COVID-19 មិនត្រូវបានធ្វើតេស្តមុនពេលអនុម័តទេ។

☑ **ការពិត៖** វ៉ាក់សាំង COVID-19 ត្រូវបានធ្វើតេស្តយ៉ាងម៉ត់ចត់មុនពេលមានការអនុម័ត។

☒ **ជំនឿខុស៖** វ៉ាក់សាំងធ្វើឱ្យអ្នកឈឺ។

☑ **ការពិត៖** បន្ទាប់ពីទទួលបានការចាក់វ៉ាក់សាំង អ្នកប្រហែលជាមានអារម្មណ៍ថាមានផលប៉ះពាល់តិចតួចដូចជាឈឺ ឬគ្រុនក្តៅតិចៗ។ នេះមានន័យថារាងកាយរបស់អ្នកកំពុងបង្កើតប្រព័ន្ធការពារ។

**ប្រភព៖**

មជ្ឈមណ្ឌលគ្រប់គ្រង និងបង្ការជំងឺ
cdc.gov/vaccine-safety/vaccines

អង្គការសុខភាពពិភពលោក
who.int/news-room/feature-stories/detail/how-do-vaccines-work

# ធនធានដែលទុកចិត្តបាន

សូមជួយបញ្ឈប់ការរីករាលដាលនៃជំនឿខុសទាក់ទងនឹងវ៉ាក់សាំង! ធនធានដែលទុកចិត្តបានទាំងនេះអាចជួយឱ្យគ្រប់គ្នាធ្វើការសម្រេចចិត្តអំពីសុខភាពសម្រាប់ខ្លួនឯង និងក្រុមគ្រួសាររបស់ពួកគេ៖

- Let's Get Real Campaign: letsgetrealaboutvaccines.org
- នាយកដ្ឋានសុខភាព Rhode Island (Rhode Island Department of Health)៖ health.ri.gov/vaccines

RHODE ISLAND DEPARTMENT OF HEALTH

# ការថែរក្សាសុខភាពរបស់អ្នកគឺជាទង្វើនៃសេចក្តីស្រឡាញ់

ទទួលបានការចាក់វ៉ាក់សាំងគឺជាសញ្ញានៃភាពរឹងមាំ។ ធ្វើវាសម្រាប់ខ្លួនអ្នក គ្រួសារអ្នក និងសហគមន៍របស់អ្នក!



វាមានសារៈសំខាន់ក្នុងការទទួលការថែទាំដែលអ្នកត្រូវការដើម្បីឱ្យមានសុខភាពល្អ។ ប្រសិនបើអ្នកមានសំណួរផ្លូវច្បាប់ទាក់ទងនឹងសិទ្ធិអន្តោប្រវេសន៍ក្នុងការចូលប្រើសេវាថែទាំសុខភាពដោយសម្ងាត់ សូម ទូរសព្ទទៅ Dorcas International តាមរយៈលេខ **401-784-8607**.

DORCAS INTERNATIONAL
INSTITUTE OF RHODE ISLAND